105

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឧទ្ធរណ៍

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ៖ ៩០៤
ចុះថ្ងៃទី០៧-១០-២០១១

**សាលដីកា**
លេខ ៖ ១០៤ ក្រ ॥
ចុះថ្ងៃទី ១២-១១-២០១២

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាឧទ្ធរណ៍ភ្នំពេញ**

បានបង្កើតឡើងតាមច្បាប់ស្តីពី ការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការ សាលាឧទ្ធរណ៍នាថ្ងៃទី១៩-១០-២០១២ ដោយមានសមាសភាពដូចខាងក្រោម៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

- ឯកឧត្តម [redacted] ជាប្រធានក្រុមប្រឹក្សា
- ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

- លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

- លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៩០៤ ចុះថ្ងៃទី ០៧-១០-២០១១ ដែលមាន ៖

**១-ជនជាប់ចោទឈ្មោះ** [redacted] ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិចំការស្បៀង សង្កាត់សំរោងក្រោម ស្រុកដង្កោ ខេត្តកណ្តាល មានទីលំនៅសព្វថ្ងៃភូមិចំការស្បៀង សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្[redacted]) ម្តាយឈ្[redacted]) នៅលីវ ទោសពីមុន គ្មាន។

-ឃាត់ខ្លួនថ្ងៃទី១១-៣-២០១០ ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣៨៥ ត.ព្រ ថ្ងៃទី១៥-៣-២០១០។

**២-ជនជាប់ចោទឈ្មោះ** [redacted]ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតភូមិត្រពាំងធ្នង សង្កាត់សំរោងក្រោម ស្រុកដង្កោ ក្រុង





Scanned by CamScanner

ភ្នំពេញ មានទីលំនៅសព្វថ្ងៃភូមិត្រពាំងឈ្វង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោ[redacted]) ម្ដាយឈ្មោ[redacted]នៅលីវ ទោសពីមុន គ្មាន។

**៣-ជនជាប់ចោទឈ្មោះ**[redacted]ៅ ត អាយុ ២០ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិត្រពាំងឈ្វង សង្កាត់សំរោងក្រោម ស្រុកដង្កោ ក្រុងភ្នំពេញ មុខរបរធ្វើស្រែ ទីលំនៅបច្ចុប្បន្នភូមិត្រពាំងឈ្វង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ឪពុកឈ្មោះ[redacted]) ម្ដាយឈ្មោ[redacted]) នៅលីវ ទោសពីមុន គ្មាន ។

**៤-ជនជាប់ចោទឈ្មោ**[redacted]ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិត្រពាំងឈ្វង់ សង្កាត់សំរោងក្រោម ស្រុកដង្កោ ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នភូមិត្រពាំងឈ្វង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ឪពុកឈ្មោះ[redacted]) ម្ដាយឈ្មោ[redacted]) នៅលីវ ទោសពីមុន គ្មាន ។

**៥-ជនជាប់ចោទឈ្មោះ** [redacted]ភេទប្រុស អាយុ ២៤ឆ្នាំជាតិខ្មែរ ទីកន្លែងកំណើតភូមិត្រពាំងឈ្វង់ សង្កាត់សំរោងក្រោម ស្រុកដង្កោ ក្រុងភ្នំពេញ មុខរបរធ្វើស្រែ ទីលំនៅបច្ចុប្បន្នភូមិត្រពាំងឈ្វង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ឪពុកឈ្មោះ [redacted]) ម្ដាយ[redacted]នៅលីវ ទោសពីមុន គ្មាន ។

**៦-ជនជាប់ចោទឈ្មោះ** [redacted] ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិត្រពាំងឈ្វង សង្កាត់សំរោងក្រោម ស្រុកដង្កោ ក្រុងភ្នំពេញ មុខរបរធ្វើស្រែ ទីលំនៅបច្ចុប្បន្នភូមិត្រពាំងឈ្វង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ឪពុកឈ្មោះ:[redacted]) ម្ដាយ[redacted]) នៅលីវ ទោសពីមុន គ្មាន ។

**៧-ជនជាប់ចោទឈ្មោះ**[redacted] ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិចំការស្បែង សង្កាត់សំរោងក្រោម ស្រុកដង្កោ ក្រុងភ្នំពេញ មុខរបរធ្វើស្រែ ទីលំនៅបច្ចុប្បន្នភូមិត្រពាំងឈ្វង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ឪពុកឈ្មោ[redacted] ម្ដាយ[redacted] នៅលីវ ទោសពីមុន គ្មាន ។

-មេធាវីលោក[redacted]ារពារឲ្យជនជាប់ចោទ

**ជាប់ចោទពីបទ: មនុស្សឃាតគិតទុកជាមុន** ប្រព្រឹត្តនៅ ភូមិត្រពាំងឈ្វង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១-១២-២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ០៣ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។



Scanned by CamScanner

105
3

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ទស្រី អាយុ ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅសព្វថ្ងៃភូមិត្រពាំងឈ្នង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]ស) ម្តាយឈ្មោះ[redacted]) ប្តីឈ្មោះ [redacted](ស) ។

**អំពីអង្គហេតុ**

តាមរបាយការណ៍សំយោគលេខ ០២/០៩ ចុះថ្ងៃទី០២-០១-២០០៩ របស់ការិយាល័យព្រហ្មទណ្ឌកំរិតធ្ងន់ និងពាក្យបណ្តឹងរបស់ជនរងគ្រោះលេខ[redacted]ះថ្ងៃទី១៧-១២-២០០៨ ដែលបានប្តឹងពីឈ្មោះ[redacted]រួមទាំងបក្សពួក ០៥នាក់ បានធ្វើសកម្មភាពប្លន់វាយប្តីឈ្មោះ[redacted]ណ្តាយអោយស្លាប់ និងយកសំភារៈមួយចំនួន ។ ក្រោយពីសមត្ថកិច្ចធ្វើការស្រាវជ្រាវរួចមក ទើបដឹងថាជនល្មើសមានចំនួន០៧នាក់គឺឈ្មោះ: [redacted]

**-ច្បានឃើញ សេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ៖ ៤៨ (ក្រ១) ចុះថ្ងៃទី ១២-៥-២០១១ សំរេចថា ៖**

១-ផ្តន្ទាទោសឈ្មោះ ៖

ក-[redacted]ហៅ រាជ ភេទប្រុស អាយុ ១៥ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៧ឆ្នាំ (ប្រាំពីរឆ្នាំ)

ខ[redacted]ភេទប្រុស អាយុ ២០ឆ្នាំ

គ-[redacted]ភេទប្រុស អាយុ ២០ឆ្នាំ

ឃ-[redacted]ភេទប្រុស អាយុ អាយុ ២៨ឆ្នាំ

ង-[redacted]ភេទប្រុស អាយុ ២២ឆ្នាំ

ច-[redacted]ទប្រុស អាយុ ២២ឆ្នាំ

ឆ-[redacted]ភេទប្រុស អាយុ ២០ឆ្នាំ

ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់រយៈពេល ១៥ឆ្នាំ (ដប់ប្រាំឆ្នាំ) ពីបទៈ មនុស្សឃាដគិតទុកជាមុន ប្រព្រឹត្តនៅភូមិត្រពាំងឈ្នង់ សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១-១២-២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងអោយផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-បង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនឈ្មោះ[redacted], [redacted]ទៅពន្ធនាគារ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-បង្គាប់ឲ្យឈ្មោ[redacted]ងអាណាព្យាបាលរបស់ឈ្មោះ មាន សំណាង រួមគ្នាសងជម្ងឺចិត្ត និងការខូចខាត



Scanned by CamScanner

ទៅអោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ចំនួន ៣០.០០០.០០០៛ (សាមសិបលានរៀល) ការទាមទារលើសពីនេះ បដិសេធចោល។

៤-វត្ថុតាងចាប់យកមានអាវវែងចំនួន ០១ ពណ៌ពងមាន់ធ្វត និងខែលផ្លៀស ចំនួន ០១ ក្រវិលរួសបំផ្លាញចោល ។

៥-សាលក្រមនេះជំនុំជម្រះថ្ងៃទី០១-៤-២០១១ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១២-៥-២០១១ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]បាំងមុខជនជាប់ចោទឈ្មោ[redacted]បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-**បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៤៦ ក្រ II ចុះថ្ងៃទី២៤-៤-២០១២ របស់សាលាឧទ្ធរណ៍ សម្រេចសេចក្តីថា:**

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៦០ ចុះថ្ងៃទី១៩-៥-២០១១ របស់ជនជាប់ចោទឈ្មោ[redacted]បណ្តឹងឧទ្ធរណ៍លេខ ៣៧៤ ចុះថ្ងៃទី២៧-៥-២០១១ របស់លោកមេធាវី នាង ហៃ បណ្តឹងឧទ្ធរណ៍លេខ ៣៩៦ ចុះថ្ងៃទី០៣-៦-២០១១ របស់លោកមេធា[redacted]ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៨ ក្រ៦"ជ" ចុះថ្ងៃទី១២-៥-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី ០២-៤-២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៤-៤-២០១២ ។ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

-**បានឃើញ** ពាក្យបណ្តឹងទាស់លេខ ៤៩ ចុះថ្ងៃទី២៨-៤-២០១២ របស់ជនជាប់ចោទឈ្មោះ:[redacted] ទាស់នឹងសាលដីកាកំបាំងមុខលេខ ៤៦ ក្រ II ចុះថ្ងៃទី២៨-៤-២០១២ របស់សាលាឧទ្ធរណ៍ គ្រប់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ:[redacted] (វត្តមាន)

-មេធាវីលោ[redacted]ការពារឲ្យជនជាប់ចោទ (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ:[redacted] (អវត្តមាន)

ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍សង្ខេបរឿង

-ជនជាប់ចោទឈ្មោ[redacted]ានឆ្លើយថា: ខ្លួនមិនសុខចិត្តព្រោះថាខ្លួនមិនបានប្រព្រឹត្តដូចបទចោទប្រកាន់ទេ ហើយក៏មិនដឹងថាម្នាក់ណាប្រព្រឹត្តដែរ សុំរួចផុតពីបទចោទប្រកាន់ ។



Scanned by CamScanner

-ជនជាប់ចោទឈ្មោះ [redacted] នឆ្លើយថា: ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ សុំរួចផុតពីបទចោទប្រកាន់ ។

-ជនជាប់ចោទឈ្មោះ [redacted] នឆ្លើយថា: ខ្លួនប្តឹងមកនេះដោយខ្លួនមិនបានប្រព្រឹត្តទេ សុំរួចផុតពីបទចោទប្រកាន់ ។

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា: ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ សុំរួចផុតពីបទចោទប្រកាន់ ។

-ជនជាប់ចោទឈ្មោ [redacted] បានឆ្លើយថា: ខ្លួនមិនបានប្រព្រឹត្តទេ សុំរួចផុតពីបទចោទប្រកាន់ ។

-ជនជាប់ចោទ [redacted] នឆ្លើយថា: ក្នុងរឿងនេះខ្លួនមិនបានប្រព្រឹត្តទេ សុំរួចផុតពីបទចោទប្រកាន់ ។

**សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ** :

ក្នុងរឿងនេះសំណូមពរ សុំក្រុមប្រឹក្សាពិចារណាសម្រេចតាមច្បាប់ចុះ ។

-មេធាវីលោក [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា: ក្នុងរឿងនេះកូនក្តីខ្លួនទាំង ៦នាក់ មិនបានប្រព្រឹត្តដូចបទចោទប្រកាន់ទេ ចំពោះរបាយការណ៍របស់ប៉ូលិស គឺធ្វើតាមការឮរបស់ប្រជាពលរដ្ឋនៅតុ ការហៀតែប៉ុណ្ណោះនៅថ្ងៃកើតហេតុកូនក្តីខ្លួនកំពុងនាំគ្នាផឹកស៊ីហើយក្រោយផឹកស៊ីបានបែកគ្នាទៅផ្ទះរៀងៗខ្លួន។ ដើមបណ្តឹងរដ្ឋប្បវេណីនៅពេលនេះបានដកបណ្តឹងឈប់ប្តឹងកូនក្តីខ្លួនទាំង ៦នាក់ នេះហើយដែរ សំណូមពរ សុំក្រុមប្រឹក្សាសម្រេចឲ្យកូនក្តីខ្លួនទាំង ៦នាក់រួចផុតពីបទចោទប្រកាន់ ។

-ក្រោយពីបានស្តាប់របាយការណ៍រឿង

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងឯកសារនានា

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

**សាលាឧទ្ធរណ៍**

**យល់ឃើញថា**

១-បណ្តឹងទាស់លេខ ៥៥ ចុះថ្ងៃទី២៨-៨-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ទាស់នឹងសាលដីកាកំបាំងមុខលេខ ៨៦ ក្រ ll ចុះថ្ងៃទី ២៧-៨-២០១២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចយករឿងនេះយកមកជំនុំជម្រះបានតាមច្បាប់ ។

២-នាពេលសួរដេញដោល ជនជាប់ចោទទាំងអស់នៅតែប្រកែកថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់អយ្យការទេ ប៉ុន្តែមានសាក្សីជាច្រើនបានឆ្លើយបញ្ជាក់



Scanned by CamScanner

ច្បាស់លាស់ពីអំពើរបស់ជនជាប់ចោទ ពេលសវនាការនៅសាលាដំបូងរាជធានីភ្នំពេញ រួចហើយ ។

៣-មេធាវីការពារឲ្យជនជាប់ចោទបានលើកឡើងថាកូនក្តីខ្លួនមិនបានប្រព្រឹត្តបទមនុស្សឃាតគិតទុកជាមុន ទេ ការដែលលោកមេធាវី សន្និដ្ឋានការពារនេះ សាលាដំបូងបានពិចារណារួចអស់ហើយ ។

៤-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានសុំដកពាក្យបណ្តឹងចុះថ្ងៃទី២៩-៦-២០១២ មិនអាចបញ្ចប់បណ្តឹងអាជ្ញាបានឡើយ ។

៥-ជនជាប់ចោទទាំងអស់ពុំបាននាំនូវភស្តុតាងដោះបន្ទុក ដែលអាចឲ្យពិចារណាបានឡើយ ពីការរួចផុតពីបទៈ **ចោទប្រកាន់** ។

៦-សាលដីកាកំបាំងមុខរបស់សាលាឧទ្ធរណ៍លេខ ៨៦ ក្រ ॥ ចុះថ្ងៃទី២៨-៨-២០១២ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ គប្បីសាលាឧទ្ធរណ៍តម្កល់សាលដីកា នេះទុកជាបានការ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងទាស់របស់ជនជាប់ចោទទាំងអស់ដូចខាងលើទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាកំបាំងមុខលេខ ៨៦ ក្រ ॥ ចុះថ្ងៃទី២៨-៨-២០១២ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី១៩-១០-២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី១២-១១-២០១២ ។ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចំលងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ,ថ្ងៃទី......ខែ......ឆ្នាំ២០១២
**ក្រឡាបញ្ជី**

[redacted]



Scanned by CamScanner